នស/រកត/០៩០៥/៣៩៤

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និង ផ្តល់សច្ចាប័ន នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី



2/7

## គ្រាស់បន្ទាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៖**

ព្រះរាជក្រឹត្យនេះកំណត់ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានអក្សរកាត់ថា **ក.ជ.ក.ស** ។ **ក.ជ.ក.ស** ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល លើបញ្ហាដែលទាក់ទងដល់ការលើកកំពស់ស្ថានភាព តួនាទីរបស់ស្ត្រី និងសុខុមាលភាពសង្គមស្ត្រីកម្ពុជា សំដៅកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងអំពើហិង្សាលើស្ត្រី ។

## ជំពូកទី ២

## សមាសភាព

**មាត្រា ២៖**

**ក.ជ.ក.ស** មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ | ព្រះប្រធានកិត្តិយស |
| ២- សម្តេចនាយករដ្ឋមន្ត្រី | អនុប្រធានកិត្តិយស |
| ៣- រដ្ឋមន្ត្រីក្រសួង កិច្ចការនារី | ប្រធាន |
| ៤- រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ១រូប អនុប្រធាន |
| ៥- រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | ១រូប អនុប្រធាន |
| ៦- រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ១រូប សមាជិក |
| ៧- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប សមាជិក |
| ៨- រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១រូប សមាជិក |
| ៩- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប សមាជិក |
| ១០-រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប សមាជិក |
| ១១-រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | ១រូប សមាជិក |
| ១២-រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប សមាជិក |
| ១៣-រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១រូប សមាជិក |

| | | |
|---|---|---|
| ១៤- រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | ១រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការ ក្រសួងពត៌មាន | ១រូប | សមាជិក |
| ១៧- រដ្ឋលេខាធិការ ក្រសួងផែនការ | ១រូប | សមាជិក |
| ១៨- រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | សមាជិក |
| ១៩- រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| ២០- រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១រូប | សមាជិក |
| ២១- រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| ២២- រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | សមាជិក |
| ២៣- រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | ១រូប | សមាជិក |
| ២៤- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ១រូប | សមាជិក |
| ២៥ - អនុប្រធាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ | ១រូប | សមាជិក |
| ២៦ - អនុប្រធាន គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ១រូប | សមាជិក |
| ២៧ - អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ១រូប | សមាជិក |

**មាត្រា ៣:**

**គ.ជ.ក.ស** មានសិទ្ធិទំនាក់ទំនងបន្ថែមជាមួយក្រសួង ស្ថាប័ននានា អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ ប្រទេសផ្តល់ជំនួយដទៃទៀតដែលពុំបានចែងក្នុងសមាសភាពនេះ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍ តាមការអញ្ជើញរបស់ **គ.ជ.ក.ស** ។

## ជំពូកទី ៣
## ភារកិច្ច រចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ គ.ជ.ក.ស

**មាត្រា ៤:**

**គ.ជ.ក.ស** មានភារកិច្ច ដូចតទៅ :

- ជួយរាជរដ្ឋាភិបាល ក្នុងការសម្របសម្រួល តាមដាន វាយតំលៃការអនុវត្ត និងផ្តល់អនុសាសន៍ ក្នុងគោលបំណងគាំទ្រ និងជំរុញការអនុវត្តគោលនយោបាយជាតិ ច្បាប់ បទបញ្ញា និងវិធានការដែលទាក់ទងដល់ការលើកកំពស់ ស្ថានភាព តួនាទី និងសុខុមាលភាពសង្គមស្ត្រីកម្ពុជា

- ជួយរាជរដ្ឋាភិបាលក្នុងការតាមដានការអនុវត្តសន្ធិសញ្ញាអន្តរជាតិនានា ពាក់ព័ន្ធទៅនឹងសិទ្ធិនារី និងការអនុវត្តច្បាប់ជាតិដែលទាក់ទងដល់ការទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងបទប្បញ្ញត្តិច្បាប់នានាដែលទាក់ទងដល់ស្ត្រី ដើម្បីផ្តល់យោបល់ លើកអនុសាសន៍ ឬសុំធ្វើវិសោធនកម្មតាមករណីជាក់ស្តែង ដើម្បីធ្វើឱ្យស្ថានភាពស្ត្រីកាន់តែប្រសើរឡើង
- សម្របសម្រួលការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទនៅព្រះរាជាណាចក្រកម្ពុជា និងពិនិត្យ ផ្តល់យោបល់ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច មុននឹងផ្ញើទៅអង្គការសហប្រជាជាតិ
- តាមដាន និងជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ និងក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល
- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពដែលក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានបំពេញ ដើម្បីផ្ញើជូនរាជរដ្ឋាភិបាល
- ពិនិត្យ និងសំរេចលើបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ក.ស**
- ទទួលភារកិច្ចផ្សេងៗទៀតតាមសំណូមពររបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥:**

**គ.ជ.ក.ស** ត្រូវមានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ ដែលមានទីតាំងនៅទីស្តីការក្រសួងកិច្ចការនារី ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ **គ.ជ.ក.ស** នឹងកំណត់ដោយអនុក្រឹត្យ ។

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើអនុរដ្ឋលេខាធិការ អមដោយអគ្គលេខាធិការរងមួយចំនួន មានឋានៈស្មើអគ្គនាយករង ដែលផ្ទេរមកបំរើការងារជាអចិន្ត្រៃយ៍នៅអគ្គលេខាធិការដ្ឋានដោយការគ្រប់គ្រងក្របខណ្ឌ និងបៀវត្សនៅក្រសួងកិច្ចការនារី និងមានមន្ត្រីមួយចំនួនទៀតផ្ទេរមកបំរើការងារជាអចិន្ត្រៃយ៍នៅអគ្គលេខាធិការដ្ឋាន **គ.ជ.ក.ស** ។

អគ្គលេខាធិការត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល អគ្គលេខាធិការរងតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ប្រធាន **គ.ជ.ក.ស** និងជារដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។

ប្រធាន **គ.ជ.ក.ស** មានសិទ្ធិតែងតាំងមុខតំណែង និងតម្លើងឋានៈមន្ត្រីនៅអគ្គលេខាធិការដ្ឋានតាមសំណើរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **គ.ជ.ក.ស** ។



517

**មាត្រា ៦:**

**គ.ជ.គ.ស** អាច :

- បង្កើតអនុគណៈកម្មការជំនាញ មានសមាសភាពទាំងពីរភេទ ដែលជាមន្ត្រីមានក្របខណ្ឌស្រាប់ ជាជំនួយការ ដើម្បីអនុវត្តតាមតម្រូវការភារកិច្ច ដូចដែលមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ
- មានទីប្រឹក្សាជាតិ និងអន្តរជាតិមួយចំនួនដែលមានសមាសភាពជាអ្នកជំនាញ ដើម្បីជួយការងារ **គ.ជ.គ.ស** និងអគ្គលេខាធិការដ្ឋាន។

**មាត្រា ៧:**

**គ.ជ.គ.ស** ត្រូវជួបប្រជុំជាសាមញ្ញរៀងរាល់ត្រីមាស ក្នុងករណីមានការចាំបាច់ **គ.ជ.គ.ស** អាចប្រជុំជាវិសាមញ្ញតាមការកោះប្រជុំ និងក្រោមអធិបតីភាពរបស់ប្រធាន **គ.ជ.គ.ស** ។ ប្រធាន **គ.ជ.គ.ស** អាចអញ្ជើញក្រសួង ស្ថាប័នដទៃទៀតចូលរួមប្រជុំខាងលើ តាមតម្រូវការចាំបាច់ ។

ក្នុងមួយឆ្នាំម្តង **គ.ជ.គ.ស** ត្រូវធ្វើការបូកសរុបរាយការណ៍ជូនអង្គប្រជុំ **គ.ជ.គ.ស** ក្រោមព្រះរាជាធិបតីភាពរបស់សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះប្រធានកិត្តិយស និងសម្តេចនាយករដ្ឋមន្ត្រី អនុប្រធានកិត្តិយស លើលទ្ធផលនៃការអនុវត្តកម្មវិធីការងារដែលត្រូវសម្របសម្រួល និងអនុសាសន៍ ដែល **គ.ជ.គ.ស** ត្រូវដាក់ចេញ ។

**មាត្រា ៨:**

**គ.ជ.គ.ស** មានបទបញ្ជាផ្ទៃក្នុង និមិត្តសញ្ញា និងត្រាមួយដោយឡែករបស់ខ្លួន ។

## ជំពូកទី ៤
## ថវិកា

**មាត្រា ៩:**

**គ.ជ.គ.ស** មានថវិកាផ្ទាល់ខ្លួនដោយឡែក ត្រូវជាឧបសម្ព័ន្ធថវិការបស់ក្រសួងកិច្ចការនារី ។ ថវិកានេះមានប្រភពទុនពីរ:

- ថវិកាជាតិ
- ជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ ប្រទេសផ្តល់អំណោយ សប្បុរសជនជាតិ ឬ បរទេស ។



៤/៤

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០:**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ និងព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១:**

សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥
**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.០៥០៨.៤០៩

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខ: ៧៥១ ច.ល
**[illegible]ចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**[illegible] តាន់**